**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:២២០ប្រ
ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៨
**<u>សាលដីកា</u>**
លេខ:២៣៣
ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៩៨

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៩៨ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ............ ជាប្រធាន
២-លោក ............... ជាចៅក្រម
៣-លោក ................ ជាចៅក្រម
៤-លោក .............. ជាចៅក្រម
៥-លោក ............ ជាចៅក្រមរបាយការណ៍

**<u>ក្រឡាបញ្ជី</u>**

-លោក ..............

**<u>តំណាងមហាអយ្យការ</u>**

-លោក ............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំនះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៣១៣ ចុះថ្ងៃទី២២-៦-៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ១៨៩ ចុះថ្ងៃទី ០៣-៦-៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ហារ៉ាមីត ស៊ីងណារ៉ូឡា ភេទប្រុស អាយុ ៤៧ ឆ្នាំជាតិខ្មែរ របរកស៊ីពាណិជ្ជករ មានទីលំនៅផ្ទះលេខ៦៣ ផ្លូវព្រះនរោត្តម សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះអាតា ស៊ីង (ស) ម្តាយឈ្មោះតៅ វ៉ាន់ទី(រ)ប្រពន្ធ ឈ្មោះ សូរីន ឌ័រ មានកូន ២នាក់ ។

តំណាងដោយឈ្មោះលោក ក្រាញ់ជ័យ លាភីតូនី ។

និងចុងបណ្តឹងសាទុក្ខឈ្មោះលោកដាំ ឆាត់វីយ៍ ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែររបររកស៊ីប្រធានអគ្គនាយកក្រុមហ៊ុន ដា ដាំ មានទីលំនៅផ្ទះលេខ៣៤B ផ្លូវ២៤០ សង្កាត់ចតុមុខ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះដាំ បូ (ស) ម្តាយឈ្មោះ គឹម បាន (ស) ។

តំណាងដោយលោក កាំង អ៊ាងឈី ភេទ ប្រុស អាយុ ៤១ ឆ្នាំ ជាតិ ខ្មែរ របរកស៊ីអនុប្រធានក្រុមហ៊ុនដា ដាំ មានទីលំនៅផ្ទះលេខ១៣២B ផ្លូ១៣៦ ក្រុម៤៧ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះកាំង ឱច(ស) ម្តាយឈ្មោះ ហួយ ញេប ប្រពន្ធឈ្មោះ ឯម សុភា ។

**<u>កម្មវត្ថុបណ្តឹង</u>** សុំកិច្ចការប្រញាប់ហាមឃាត់វិញ្ញាបនបត្រ(ច្បាប់ដើម)លោហៈធាតុប្លាកទីនលេខCDN$^{0}$៨១៨០៩ A២៧៨៨៩

បានឃើញបណ្តឹងសាទុក្ខលេខ២៥៣ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៨ របស់ឈ្មោះប៉ាង សុធា មេធាវីឱ្យឈ្មោះ ហារ៉ាមីត ស៊ីងណារ៉ូឡា បានប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចនៃសាលដីកាលេខ៣១៣ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២២០ប្រ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៨ របស់ឈ្មោះដាំ ឆាត់រីយ៍ ប្តឹងសុំហាមឃាត់ការលក់ដូរ ផ្ទេរ ធ្វើសម្បទានបញ្ញាវិញ្ញាបនបត្រលោកហៈធាតុប្លាទីនលេខសេដេ ៨១៨០៩អា ២៧៨៨៩ ដែលមានតម្លៃចំនួនមួយពាន់បួនរយលានដុល្លាអាមេរិក និងទាមទារយកវិក័យបត្រច្បាប់ដើមលោហៈធាតុប្លាទីនលេខដូចខាងលើនេះ ដែលជារបស់ខ្លួន ហើយសព្វថ្ងៃនៅលើដៃលោក ហាមីត ស៊ីង មកប្រគល់ឱ្យ ខ្លួនវិញ ដោយសំអាងហេតុថា ខ្លួនបានប្រគល់សិទ្ធិចាត់ចែងការងារលិខិតលេខRC៩៧០០២ CDDC ចុះថ្ងៃទី២៣-១២-៩៧ ទៅលោកWILFREDOS SAURIN ជនជាតិហ្វីលីពីន ដែលជាសហការីរបស់ខ្លួនផ្ទាល់ និងលោក ហាមីត ស៊ីង សញ្ជាតិថៃ កាន់លិខិតឆ្លងដែនលេខS ២៨៤២៣៨ បន្ទាប់ពីបានទទួលលិខិតប្រជល់សិទ្ធិនេះហើយ គេទាំងពីរនាក់ក៏ចេញទៅបរទេសទៅប្រកបកិច្ចការរៀងៗខ្លួន ដោយកាន់ទៅជាមួយវិញ្ញាបនបត្រច្បាប់ដើមចំនួន៣ រួមទាំងវិញ្ញាបនបត្រលោហៈធាតុប្លាទីនលេខCDN ៨១៨០៩ អា ២៧.៨៨៩ ដែលមានតម្លៃចំនួនមួយពាន់បួនរយលានដុល្លា១៤០០,០០០,០០០ ។

លោក ហាមីត ស៊ីង បានរត់លេចខ្លួនទៅប្រទេសអឺរ៉ុប ដោយយកទៅជាមួយនូវច្បាប់ដើមនៃវិញ្ញាបនប័ត្រ ដូចរៀបរាប់ខាងលើបណ្តាលឱ្យភ្ញៀវរបស់ខ្លួនជាច្រើននាក់ រួមទាំងខ្លួនដែលចចារគ្នាត្រូវអស់ហើយក្នុងការទិញ លក់វិញ្ញាបនបត្រនេះ មានការរាំងស្ទះកិច្ចការរួមទាំងខូចខាតផលប្រយោជន៍ និងប្រាក់កាសជាច្រើន ។ ដោយលោក ហាមីត ស៊ីង នៅតែមិនព្រមប្រគល់វិញ្ញាបនបត្រនេះ មកឱ្យខ្លួនជាម្ចាស់ ខ្លួនគ្មានផ្លូវជ្រើសរើសក្រៅពីធ្វើសេចក្តីប្រកាសបដិសេធមិនទទួលស្គាល់នូវលិខិតរបស់ខ្លួនចុះថ្ងៃទី២៣-១២-៩៨ ហើយហាមប្រាមមិនឱ្យភ្ញៀវ ទាក់ទងធ្វើអាជីវកម្មជាមួយគាត់ពាក់ព័ន្ធនឹងវិញ្ញាបនបត្រនេះ ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខខ១៥ប្រ.ក ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៨ របស់សតុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងទាស់សុំលុបដីកាសម្រេចតាមពាក្យសុំលេខ១៦(ក) ចុះថ្ងៃទី២៨-០៤-៩៨ ដែលចេញដោយតុលាការក្រុងភ្នំពេញ របស់ឈ្មោះ ហារ៉ាមីត ស៊ីងណារ៉ូឡា ចុះថ្ងៃទី ២៨-០៤-៩៨ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-លុបចោដិកាសម្រេចតាមពាក្យសុំលេខ១៦(ក) ចុះថ្ងៃទី២៨-០៤-៩៨ រសប់តុលាការក្រុងភ្នំពេញ ចាប់តាំងពីថ្ងៃនេះតទៅ ។

៣-បង្គាប់ឱ្យឈ្មោះហារ៉ាមីត ស៊ីងណារ៉ូឡា បង់ប្រាក់ប្រដាប់ក្តី ២០០០រៀល ។

៤-ដីកានេះមានអនុភាពយកទៅអនុវត្តភ្លាមៗ ទោះបីមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៤០ (ក) ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៨ របសលោកកាំង អ៊ាងឈី ដែលប្តឹងជំទាស់នឹងដីកាសម្រេចកិច្ចការប្រញាប់លេខ១៥ប្រក. ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៣១៣ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍សម្រេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ៤០(ក) ចុះថ្ងៃទី២៥-៥-៩៨ របស់ឈ្មោះកាំង អ៊ីសងឈី ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- បដិសេធដីកាសម្រេចកិច្ចការប្រញាប់លេខ១៥ប្រក. ចុះថ្ងៃទី១៣-៥-៩៨ របស់តុលាការ ក្រុងភ្នំពេញចោលជាអាសារបង់ ។

៣- ហាមឃាត់ឈ្មោះហាមីត ស៊ីង ហៅណារ៉ូឡា ភេទប្រុសអាយុ៤៧ឆ្នាំ មិនឱ្យលក់ដូរ ផ្ទេរសិទ្ធិ ធ្វើសម្បទាន បញ្ចាំនូវវិញ្ញាបនបត្រលោហៈធាតុថ្លាទីនលេខCDNº ៨១៨០៩ អា២៧៨៨៩ ជាបណ្តោះអាសន្នសិន រង់ចាំតុលាការសម្រេចដល់អង្គសេចក្តី ។

៤. បង្គាប់ឱ្យឈ្មោះហាមីត ស៊ីង ហៅ ណារ៉ូឡា ភេទប្រុស អាយុ ៤៧ឆ្នាំ យកវិញ្ញាបនបត្រ(ច្បាប់ដើម) លោហៈធាតុថ្លាទីនលេខ CDNº ៨១៨០៩ អា២៧៨៨៩ យកមកប្រគល់ឲ្យឈ្មោះដាំ ឆាត់រីយ៍ ភេទប្រុស អាយុ៤៨ ឆ្នាំ ជាGroup chairman of CHEAM DAMGROUP OF COMPANIES ទុកជាបណ្តោះអាសន្នរង់ចាំតុលាការសម្រេចដល់អង្គសេចក្តី ។

៥. សម្រេចកាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ៥.០០០រៀល និងលើអាជ្ញាធរតុលាការ ៥.០០០រៀល ។

៦- សាលដីកានេះមានប្រសិទ្ធិភាពអនុវត្តភ្លាមៗ ទោះបីមានបណ្តឹងសាទុក្ខក៏ដោយ ។

សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខឈ្មោះកាំង អ៊ាងឈី អ្នកទទួលសិទ្ធិរបស់លោកហាមីត ស៊ីង មេធាវីលោកហាមីត ស៊ីង ។ បើកផ្លូវសាទុក្ខក្នុងក្នុងកំណត់ច្បាប់។

បានឃើញបណ្តឹងសាទុក្ខលេខ២៥៣ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៨ របស់ឈ្មោះលោកប៉ាង សុជា មេធាវីលោក ហារ៉ាមីត ស៊ីងណារ៉ូឡា បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៣១៣ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៨ របសសាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី១៩-១០-៩៨ របស់ឈ្មោះ ហារ៉ាមីត ស៊ីងណារ៉ូឡា

បានឃើញសារណាតប ចុះថ្ងៃទី១៩-១០-៩៨ របស់ឈ្មោះកាំង អ៊ាងឈី

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

បណ្តឹងសាទុក្ខរបស់លោកប៉ាង សុជា មេធាវីឲ្យលោក ហារ៉ាមីត ស៊ីងណារ៉ូឡា ស្ថិតនៅក្នុងកំណត់ច្បាប គម្បីលើកយករឿងនេះមកពិនិត្យពិចារណា ។

-សាលដីការដ្ឋប្បវេណីលេខ៣១៣ ចុះថ្ងៃទី២២-៦-៩៨ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចត្រឹមត្រូវតាមគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិចារណាតាមច្បាប់តទៅ ។

ក្រឡាបញ្ជីអានសារណារបស់ឈ្មោះហារ៉ាមីត ស៊ីងណារ៉ូឡា ជាដើមចោទនិងជាដើមបណ្តឹងសាទុក្ខ ។

បានស្តាប់ចម្លើយរបស់ឈ្មោះកាំង អ៊ាងឈី តំណាងឱ្យឈ្មោះដាំ ឆារីយ៍ ជាចុងចម្លើយ និងជាចុងបណ្តឹងសាទុក្ខនៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថា

-ហាអារ៉ាមីត ស៊ីងណារ៉ូឡា នេះកុហក់តុលាការអំពីឈ្មោះរបស់ខ្លួន ព្រោះមានឈ្មោះដល់ទៅបី គឺកុហក់ទាំងអាយុ ទាំងឪពុកម្តាយ ។ ខ្លួនសំណូមពរឱ្យតុលាការស្រាវជ្រាវប្រវត្តិរបស់ឈ្មោះនេះ ។

-ឈ្មោះនេះនិយាយថាមិនបានទទួលវិញ្ញាបនបត្រគឺមិនពិតទេ ព្រោះថាឈ្មោះនេះបានយកលិខិត វិញ្ញាបនបត្រទៅឱ្យឈ្មោះលី វ៉ា ជនជាតិចិន ម៉្យាងទៀតមេធាវីប៉ាង សុជា និយាយនៅសាលាឧទ្ធរណ៍ថា : កូនខ្លួនបានទទួលវិញ្ញាបនបត្រដល់ទៅ៣ ដូច្នេះគឺបញ្ជាក់ថាឈ្មោះនេះ ពិតជាបានទទួលវិញ្ញាបនបត្រ ទនាស់នេះពិតប្រាកដមែន ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់លោក ហារ៉ាមីត ស៊ីងណារ៉ូឡា និង ចម្លើយរបស់លោកកាំង អ៊ាងឈី តំណាងឱ្យលោកដាំ ឆាត់រីយ៍

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៥៣ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៨ របស់លោកប៉ាង សុជា មេធាវីរបស់លោកហារ៉ាមីត ស៊ីងណារ៉ូឡា ធ្វើឡើងក្នុងតំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា នៅក្នុងសំណុំរឿងនេះ ដើមចោទតែម្នាក់ មានឈ្មោះបីផ្សេងគ្នាគឺ ៖

+ឈ្មោះណារ៉ាមីត ស៊ីណារ៉ូឡា ឈ្មោះនេះកំណត់តាមការអះអាងរបស់សាម៉ីខ្លួន

+ឈ្មោះណារ៉ាមីត ឈ្មោះនេះយកតាមអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

+ឈ្មោះហាមីតស៊ីង ឈ្មោះនេះយកតាមលិខិតឆ្លងដែនរបស់ព្រះរាជាណាចក្រថៃឡង់ដ៍

ដូច្នេះទោះបីតុលាការសម្រេច សេចក្តីពាក់ព័ន្ធនឹងឈ្មោះណាមួយ ក្នុងចំណោមឈ្មោះទាំងបីនេះ ក៏ដោយក៏អាចអនុវត្តសេចក្តីសម្រេចនោះបានដូចគ្នា ពីព្រោះឈ្មោះទាំងនេះសំគាល់ទៅលើមនុស្សតែម្នាក់ ។

-យល់ឃើញថា ការដែលលោកហារ៉ាមីត ស៊ីងណារ៉ូឡា លើកឡើងក្នុងសារណារបស់លោក ចុះថ្ងៃទី១៩-១០-៩៨ ថាលោកដាំ ឆាត់រីយ៍ មិនបានបំពេញកាតព្វកិច្ចប្រគល់វិញ្ញាបនបត្រទំនាស់ ឱ្យលោកទេ ហើយក៏គ្មានភស្តុតាងណាមួយបញ្ជាក់ថា លោកបានទទួលនូវវិញ្ញាបនបត្រនោះគឺ ជាការមិនត្រឹមត្រូវទេ ពីព្រោះថាលិខតបទបញ្ជា ចុះថ្ងៃទី០៧-១២-៩៧ និងលិខិតប្រគល់សិទ្ធិធ្វើពាណិជ្ជកម្មទ្រព្យសម្បត្តិដោយ គ្មានលក្ខខ័ណ្ឌចុះថ្ងៃទី២៣-១២-៩៧ ដែលលោកបានចុះហត្ថលេខានោះ សុទ្ធតែបញ្ជាក់ថា លោកហាមីត ស៊ីង និងលោក វិលប្រែដូស សៅរិន បានទទួលយវិញ្ញាបនបត្រទំនាស់នេះនៅថ្ងៃចុះហត្ថលេខា និងនៅទីកន្លែង ដែលចុះហត្ថលេខាប្រាកដណាស់ ។ ម៉្យាងទៀតលិខិតប្រគល់ និងផ្ទេរសិទ្ធិចុះថ្ងៃទី១៤-៤-៩៨ ពីលោកហាមីត ស៊ីង ទៅលោក Li wah ជាភស្តុតាងបញ្ជាក់ថា វិញ្ញាបនបត្រលោហៈធាតុថ្លាទីនទំនាស់នេះពិត ជាលោកបានទទួលពីលោកដាំ ឆាត់រីយ៍ រួចហើយ ។

-យល់ឃើញថាលោក ហារ៉ាមីត ស៊ីងណារ៉ូឡា បានធ្វើសារណាការពាររឿងក្តីរបស់លោក ជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែលោក និង តំណាងរបស់លោកពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះ តុលាការកំពូលជំនុំជំរះរឿងនេះកិបាំងមុខលោក ប៉ុន្តែទាត់ទុកជាទំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៣១៣ ចុះថ្ងៃទី២២-៦-៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខតំណាងលោកដាំ ឆាត់រីយ៍ កំប្លាំងមុខ លោកហារ៉ាមីត ស៊ីងណារ៉ូឡា

និង តំណាងរបស់លោក ប៉ុន្តែចាត់ទុកជាចំពោះមុខ.

១- ទទួលបណ្ដឹងសាទុក្ខលេខ២៥៣ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៨ របស់លោកប៉ាង សុជា មេធាវីលោកហារ៉ាមីត ស៊ីងណារ៉ូឡា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងតតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ៣១៣ ចុះថ្ងៃទី២២-៦-៩៨ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣. រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន ១៩.០០០រៀល ដែលលោកដាំ ឆាត់រីយ៍ បានបង់ជួសរួច ហើយគឺ ៖

-ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្នឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់រឹបប្រាក់ ,

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ហើយតម្រូវឱ្យលោកហារ៉ាមីត ស៊ីងណារ៉ូឡា សងប្រាក់ចំនួន ១៩០០០រៀលនេះ ទៅលោកដាំ ឆាត់រីយ៍ វិញ ។

៤- សាលដីកានេះ ប្រកាសនោសនាការ ជាសាធារណៈ នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៩៨ ។